# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិក អាជ្ញាធរសវនកម្មជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ឆ្នាំ ២០០២ ។
- តាមសំណើរបស់អគ្គសវនករ

## សំរេច

**មាត្រា ១ :** អនុក្រឹត្យនេះកំណត់ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២ :** ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិត្រូវកត់ត្រាក្នុងជំពូក ១០ នៃមាតិកាថវិការដ្ឋ ។

**មាត្រា ៣ :** អគ្គសវនករ អគ្គសវនកររង អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបានទទួលប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗប្រចាំខែតាមការកំណត់ដូចខាងក្រោមចាប់ពីថ្ងៃទទួលភារកិច្ច :

- អគ្គសវនករត្រូវបាន : ៦.៣៣៧.០០០៛
- អគ្គសវនកររងត្រូវបាន : ៤.៩៣០.០០០៛
- អគ្គលេខាធិការត្រូវបាន : ៣.៦៤១.៦០០៛
- អគ្គលេខាធិការរងត្រូវបាន : ២.៩៨០.១០០៛

**មាត្រា ៤ :** ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិ ដែលមិនបានចែងក្នុងប្រការ ៣ ត្រូវស្ថិតនៅក្រោមការពិនិត្យ និងសំរេចរបស់អគ្គសវនករ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**អគ្គសវនករ**

**អ៊ុត ឈន**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចមានមាត្រា ៥
- ឯកសារ-កាលប្បវត្តិ